# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម

**សំណុំរឿង០០២ / របាយការណ៍ លេខ ១ / សវនាការបឋម / ២៧-៣០ មិថុនា ២០១១**




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*យ៉ាងហោចណាស់ ក៏ការជំនុំជម្រះនេះអាចស្វែងរកការពិត*
*អាចទទួលស្គាល់ហេតុការណ៍ដែលបានកើតឡើង អាចផ្តល់នូវភាពស្ងប់ចិត្តសម្រាប់ជនរងគ្រោះ*
*និងអាចបិទទំព័រនៃការឈឺចាប់។*

ដោយមេធាវីអន្តរជាតិ **ម៉ាទីន ហ្សាក់ឃ្វីន** មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

## I. **ទិដ្ឋភាពទូទៅ**

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ អង្គជំនុំជម្រះនៃ អ.វ.ត.ក បានចាប់ផ្តើមសវនាការបឋម ក្នុងសំណុំរឿងក្តីប្រឆាំងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ចំនួន៤រូប រួមមាន លោក **នួន ជា** លោក **អៀង សារី** អ្នកស្រី **អៀង ធីរិទ្ធ** និងលោក **ខៀវ សំផន**។ សវនាការនេះ ជាព្រឹត្តិការណ៍ចាប់ផ្តើមជាផ្លូវការណ៍នៃដំណើរការជំនុំជម្រះក្តី យោងតាមវិធាន ៨០ ស្ទួន[1]។ ក្នុងអំឡុងពេលសវនាការ អង្គជំនុំជម្រះបានពិចារណាទៅលើបញ្ជីឈ្មោះសាក្សី និងលក្ខខណ្ឌលម្អិតអំពីការផ្តល់សំណងដែលសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទាមទារតាមវិធាន ២៣ ស្ទួនបួន (៣) (ខ)។ ភាគីទាំងឡាយបានបង្ហាញនូវទឡ្ហីករណ៍ផ្លូវច្បាប់ ដូចតទៅ ៖ (១) គោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ (២) ការលើកលែងទោសលើលោក **អៀង សារី** ដោយអតីតព្រះមហាក្សត្រនរោត្តមសីហនុ (៣) អាជ្ញាយុកាលនៃការរំលោភបំពានធ្ងន់

ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និង (៤) អាជ្ញាយុកាលនៃបទល្មើសថ្នាក់ជាតិ ដែល អ.វ.ត.ក មានដែនយុត្តាធិការ។

ជនជាប់ចោទទាំងបួនរូប ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បទប្រល័យពូជសាសន៍[2] ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មនានាមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ រួមមាន អំពើមនុស្សឃាត អំពើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះបានបង្ហាញឲ្យដឹងថា ជនជាប់ចោទក៏ទទួលខុសត្រូវទៅលើ "**សហឧក្រិដ្ឋកម្មរួម**" ទាំងទៅលើអំពើសកម្ម និងអំពើអកម្ម ដែលបានប្រព្រឹត្តិនៅក្នុងប្រទេសកម្ពុជា ចន្លោះថ្ងៃទី១៧ មេសា ២៩៧៥ ដល់ ៦ មករា ១៩៧៩។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ បានចោទប្រកាន់បន្ថែមថា ជនជាប់ចោទក៏ត្រូវទទួលខុសត្រូវផងដែរ ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និង/ឬជំនួយ ឬការជំរុញចារីក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋដូចបានចោទប្រកាន់ និង/ឬថាជនជាប់ចោទមានពិរុទ្ធិទទួលខុសត្រូវក្នុងការចេញបញ្ជា (command responsibility)។

បន្ថែមលើរបៀបវារៈនៃការសួរដេញដោលផ្នែកច្បាប់ដូចបានកំណត់ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យជនជាប់ចោទ **នួន ជា** ឡើងថ្លែងនូវកង្វល់របស់ខ្លួន បន្ទាប់ពីជនជាប់ចោទលើកឡើងថាខ្លួននឹងដើរចេញពីសាវនាការនៅថ្ងៃនោះ ប្រសិនណាបញ្ហារបស់គាត់មិនត្រូវយកមកដោះស្រាយនោះទេ។ ដំបូងឡើយ **នួន ជា** ប្រកាសថា គាត់ "មិនសប្បាយចិត្ត"[3] ជាមួយនឹងរបៀបវារៈរបស់អង្គជំនុំជម្រះ ហើយបានសំណូមពរសុំការអនុញ្ញាតឲ្យមេធាវីរបស់គាត់ឡើងថ្លែងអំពីបញ្ហាទាំងនោះ ដែលមិនស្ថិតនៅក្នុងរបៀបវារៈទេ។ ចៅក្រម **និល ណុន** ប្រធានអង្គជំនុំជម្រះ បានបដិសេធនឹងសំណូមពររបស់លោក **នួន ជា** បន្ទាប់ក្រោយមកមេធាវីការពារក្តីអន្តរជាតិរបស់គាត់ លោក **មីឈែល ផេសមែន** បានបន្តទទូចលើកនូវបញ្ហាទាំងនេះ។ លោក **ផេសមែន** បានថ្លែងអំពីការជំទាស់របស់កូនក្តីគាត់ ចំពោះនីតិវិធីដែលចៅក្រមស៊ើបអង្កេតបានអនុវត្តក្នុងដំណាក់កាលស៊ើបអង្កេត ។ គាត់បានបញ្ជាក់ឡើងវិញនូវការទាមទាររបស់កូនក្តីថា អង្គជំនុំជម្រះសាលាដំបូងគួរអនុញ្ញាតិឲ្យលោក **នួន ជា** អាចកោះអញ្ជើញសាក្សីទាំង ៣០០នាក់ មកផ្តល់សក្ខីកម្មនៅចំពោះមុខតុលាការ។ អ្វីដែលសំខាន់នោះ លោក **ផេសមែន** បានជម្រាបទៅកាន់តុលាការថា ប្រសិនបើបញ្ហារបស់លោក **នួន ជា** និងសាក្សីទាំងអស់របស់គាត់មិនត្រូវបានបញ្ចូលក្នុងការពិភាក្សានោះទេ កូនក្តីរបស់គាត់នឹងមិនចូលរួមក្នុងដំណើរការនីតិវិធីទេ[4]។ បន្តិចក្រោយមកលោក **នួន ជា** បានសំណូមពរសុំចាកចេញពីបន្ទប់សវនាការ ដោយគាត់បានបញ្ជាក់ថា គាត់នឹងត្រឡប់មកវិញលុះត្រាណាបញ្ហារបស់គាត់ត្រូវបានយកមកដោះស្រាយជាសាធារណៈ។ អង្គជំនុំជម្រះក៏បានអនុញ្ញាតតាមសំណើលោក **នួន ជា** ឲ្យចាកចេញពីបន្ទប់សវនាការ។

## II. បញ្ហាផ្លូវច្បាប់ និងនីតិវិធី

### ក. គោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ

នៅពេលចាប់ផ្ដើមសវនាការ សហមេធាវីការពារក្ដីរបស់ជនជាប់ចោទ **អៀង សារី** បានលើកឡើងអំពីគោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ ដែលជាគោលការណ៍ហាមឃាត់មិនឱ្យកាត់ទោសបុគ្គលម្នាក់ពីរដងទៅលើបទល្មើសដដែល[5]។

ក្រុមមេធាវីការពារក្ដីស្នើសុំឱ្យបញ្ឈប់ដំណើរការនីតិវិធីប្រឆាំងនឹងលោក **អៀង សារី** ពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មនានា ដោយសំអាងហេតុថា លោក **អៀង សារី** ត្រូវបានកាត់ទោសដោយកំបាំងមុខម្ដងរួចហើយ និងផ្ដន្ទាទោសពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មនានា ដោយតុលាការបដិវត្តន៍ប្រជាជន ក្នុងឆ្នាំ១៩៧៩ (**តុលាការឆ្នាំ១៩៧៩**) នៅទីក្រុងភ្នំពេញ។ ការអនុវត្តន៍គោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ នឹងគ្របដណ្ដប់លើដែនយុត្តាធិការរបស់ អ.វ.ត.ក ទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងអាចជាឧក្រិដ្ឋកម្មនានា ដែលតុលាការឆ្នាំ១៩៧៩ បានផ្ដន្ទាទោសលើលោក **អៀង សារី**។ គោលការណ៍នេះ អាចមានប្រសិទ្ធិភាពបញ្ឈប់រាល់នីតិវិធីទាំងឡាយប្រឆាំងនឹងលោក **អៀង សារី**។

នៅក្នុងសេចក្ដីសម្រេចចុះថ្ងៃទី១៣ មករា ២០១១[6] អង្គបុរេជំនុំជម្រះបានសម្រេចថា គោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ មិនរារាំងដល់ការកាត់ក្ដីលើលោក **អៀង សារី** នៅ អ.វ.ត.ក ទេ។ អង្គបុរេជំនុំជម្រះបានលើកសំអាងហេតុដូចតទៅ ៖ **ទីមួយ** គោលការណ៍ដែលបានចែងនៅក្នុងមាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គឺហាមមិនឱ្យមានការកាត់ទោសច្រើនដង ក្នុងករណីដែលលទ្ធផលពុំរកឃើញពិរុទ្ធិភាព និងដោះលែងឱ្យមានសេរីភាព មិនមែនជាការផ្ដន្ទាទោសទេ។ **ទីពីរ** គោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ គឺមានដែនអនុវត្តកម្រិតថ្នាក់ជាតិប៉ុណ្ណោះ ដូចមានចែងនៅក្នុងអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ អង្គបុរេជំនុំជម្រះបានបន្ដលើកហេតុផលថា គោលការណ៍នេះមិនអនុវត្តនៅ អ.វ.ត.ក ទេ ពីព្រោះតុលាការនេះជាតុលាការ "មានលក្ខណៈជាអន្តរជាតិ"។ **ទីបី** សេចក្ដីសម្រេចនេះក៏បានពន្យល់ថា តាមរយៈវិធាននីតិវិធីនៅក្នុងកម្រិតស្ដង់ដារអន្តរជាតិ[7] តុលាការកាត់ទោសលើលោក **អៀង សារី** ក្នុងឆ្នាំ១៩៧៩ មិនអាចអនុវត្តន៍គោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយបានទេ នេះជាករណីលើកលែង ដោយសារតែតុលាការមិនបានធ្វើឡើងដោយភាពឯករាជ្យ និងមិនលំអៀង ព្រមទាំងត្រឹមត្រូវតាមនីតិវិធីច្បាប់។

ក្នុងអំឡុងពេលសវនាការបឋម ក្រុមមេធាវីការពារក្តីរបស់លោក **អៀង សារី** បានជំទាស់ទៅនឹងសេចក្តីសម្រេចទាំងឡាយរបស់អង្គបុរេជំនុំជម្រះ។ ក្រុមមេធាវីបានលើកឡើងថា មិនចាំបាច់ធ្វើការបកស្រាយមាត្រា១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ ព្រោះថា ការជំនុំជម្រះលើលោក **អៀង សារី** ពិតជាត្រូវបានហាមឃាត់នៅក្នុងគោលការណ៍នៃមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធនឹង "**អាជ្ញាអស់ជំនុំ**" ដែលជាមូលដ្ឋាននៃការរំលត់បណ្តឹងអាជ្ញា។ មេធាវីការពារក្តីបានបន្តទៀតថា ថ្វីត្បិតតែអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វាជាការចាំបាច់ក្នុងការអនុវត្តន៍មាត្រា១២ តែជាមួយនឹងមាត្រា៧ មាត្រា១២ត្រូវបានបកស្រាយក្នុងការសម្រេចសេចក្តីចុងក្រោយ មិនថាសាលក្រមនោះសម្រេចឲ្យរួចខ្លួន ឬត្រូវផ្តន្ទាទោស។ តុលាការឆ្នាំ១៩៧៩ បានកាត់ក្តីលើករណីរបស់លោក **អៀង សារី** ដោយជាក់ច្បាស់ ព្រមទាំងមានសាលក្រមផ្តន្ទាទោសទៀតផង ដូចនេះមានន័យថា ករណីរបស់លោក **អៀង សារី** គឺស្ថិតក្នុងអាជ្ញាអស់ជំនុំ "សំណុំរឿងដែលបានផ្តន្ទាទោសរួចហើយ" ហេតុដូច្នេះបណ្តឹងអាជ្ញាប្រឆាំងលើរូបកូនក្តីគាត់ ត្រូវតែបញ្ចប់។ ឆ្លើយតបទៅនឹងសេចក្តីសម្រេចទី២របស់អង្គបុរេជំនុំជម្រះ មេធាវីការពារក្តីរបស់លោក **អៀង សារី** បានអះអាងថា អ.វ.ត.ក គឺជាតុលាការជាតិ ព្រោះអនុវត្តប្រព័ន្ធនីតិវិធីក្នុងស្រុក មិនមែនជាតុលាការ "ខ្នាតអន្តរជាតិ" ទេ។ ដូច្នេះ សិទ្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គួរតែអនុវត្តនៅក្នុងដំណើរការនីតិវិធីនៅ អ.វ.ត.ក។ ជាចុងបញ្ចប់ មេធាវីការពារក្តីរបស់លោក **អៀង សារី** បានស្នើឡើងថា មិនត្រូវមានករណីលើកលែងណាមួយយកមកអនុវត្តចំពោះគោលការណ៍ជំនុំជម្រះក្តីដោយយុត្តិធម៌ទេ (ពិសេសទាក់ទងនឹងការមិនកាត់ទោសពីរដងលើបទល្មើសតែមួយ) ព្រោះថាលោក **អៀង សារី** ត្រូវបានផ្តន្ទាទោសរួចហើយ ហើយនិងមានសាលក្រមស្ថាពរ ដែលកើតចេញពីដំណើរការនីតិវិធីនៅក្នុងសម័យនោះ ។

ឆ្លើយតបទៅនឹងបញ្ហានេះ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា អាជ្ញាអស់ជំនុំនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា មិនជាប់ពាក់ព័ន្ធនឹងករណីរបស់លោក **អៀង សារី** ទេ ព្រោះថាប្រការនេះអនុវត្តបានសម្រាប់តែសាលក្រមសម្រេចឲ្យរួចខ្លួនប៉ុណ្ណោះ ដើម្បីឲ្យជនដែលត្រូវគេផ្តន្ទាទោសអាចជំទាស់ទៅនឹងសេចក្តីវិនិច្ឆ័យទៅលើពួកគេ ដូចមានចែងនៅក្នុងមាត្រា៣៦៥ មាត្រា៣៧០ និងមាត្រា៣៧១ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ ចំណែកឯការអះអាងផ្អែកលើសិទ្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សហព្រះរាជអាជ្ញាអន្តរជាតិលោក **ខេយលី** បានថ្លែងបញ្ជាក់ថា អនុសញ្ញានេះមិនអាចអនុវត្តបានទេចំពោះដំណើរការក្តីនៅ អ.វ.ត.ក ដែលចំណុចនេះ អង្គជំនុំជម្រះបានបញ្ជាក់រួចហើយថា អ.វ.ត.ក គឺ ជា "តុលាការមួយឯករាជ្យ ដែលបង្កើតឡើងដោយច្បាប់ដាច់ដោយឡែក និងមានលក្ខណៈអន្តរជាតិ"[8] នៅក្នុងសេចក្តីសម្រេចមួយកាលពីថ្ងៃទី ១៥ មិថុនា ២០០៩។ អ.វ.ត.ក មានលក្ខណៈពិសេសមួយ គឺជំនុំជម្រះតែលើសំណុំរឿងទាំងឡាយណាដែលស្ថិតនៅក្រៅវង្វង់កំណត់របស់សិទ្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ជាចុងក្រោយ សហព្រះ

រាជអាជ្ញាបានលើកទឡ្ហីករណ៍ថា សាលក្រមផ្តន្ទាទោសលោក **អៀង សារី** ដោយតុលាការឆ្នាំ១៩៧៩ គឺមិនបានអនុវត្តទេ ដែលមិនមានកតព្វកិច្ចចងភ្ជាប់ទៅនឹងគោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ និងម្យ៉ាងទៀត ដំណើរការនីតិវិធីនៅចំពោះមុខតុលាការបដិវត្តន៍ប្រជាជន មិនត្រូវបានធ្វើឡើងស្របតាមបទដ្ឋាននៃគោលការណ៍ជំនុំជម្រះក្តីដោយយុត្តិធម៌។ ដើម្បីគាំទ្រទៅលើទឡ្ហីករណ៍នេះ សហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ថា តុលាការបដិវត្តន៍ប្រជាជន មិនបានបង្កើតឡើងដោយច្បាប់ តែបង្កើតឡើងដោយក្រិត្យច្បាប់ចេញដោយក្រុមប្រឹក្សាបដិវត្តន៍ប្រជាជនកម្ពុជា។ លោក **ខេយលី** បានពន្យល់ថា ក្រិត្យច្បាប់នេះ "បានបញ្ជាក់អំពីទស្សនៈរបស់ស្ថាប័ននីតិប្រតិបត្តិនៃរដ្ឋាភិបាលកម្ពុជា អំពីពិរុទ្ធិភាពរបស់ជនជាប់ចោទ **អៀង សារី** និង **ប៉ុល ពត** រួចទៅហើយមិនទាន់ទាំងបានធ្វើការស៊ើបអង្កេត ឬតុលាការចាប់ផ្តើមដំណើរការផង"[9]។ លោក **ខេយលី** បន្តទៀតថា តុលាការបដិវត្តន៍ប្រជាជន បានធ្វើការវិនិច្ឆ័យទុកជាមុនអំពីពិរុទ្ធិភាពរបស់ **ប៉ុន ពត** និង **អៀង សារី** ដែលមានភស្តុតាង គឺសេចក្តីប្រកាសជាសាធារណៈនៅក្នុងសន្និសីទសារព័ត៌មានដោយលោក **កែវ ចិន្តា** ប្រធានតុលាការនេះ ធ្វើមុនពេលចាប់ផ្តើមការសវនាការ។

### ខ. ការលើកលែងទោស និងការព្រះរាជទានលើកលែងទោស

បន្ទាប់ពីការស្តាប់នូវទឡ្ហីករណ៍លើប្រធានបទគោលការណ៍មិនកាត់ទោសពីរដងលើបទល្មើសតែមួយ អង្គជំនុំជម្រះសាលាដំបូង បានពិភាក្សាលើប្រធានបទទាក់ទងនឹងការលើកលែងទោស ដែលលើកឡើងដោយក្រុមមេធាវីការពារក្តីលោក **អៀង សារី** ។

ក្រោយពីការកាត់ទោសកំបាំងមុខក្នុងឆ្នាំ១៩៧៩ លោក **អៀង សារី** ត្រូវបានកាត់ទោសប្រហារជីវិត និងរឹបអូសទ្រព្យសម្បត្តិទាំងអស់របស់គាត់។ ក៏ប៉ុន្តែ សាលក្រមនេះមិនបានអនុវត្តឡើយ និងនៅឆ្នាំ១៩៩៦ ព្រះមហាក្សត្រ **នរោត្តម សីហនុ** បានព្រះរាជទានលើកលែងទោសដល់រូបលោក ។ "**ការលើកលែងទោស**" នេះមានវិសាលភាពគ្របដណ្តប់លើទោសទណ្ឌគ្រប់ប្រភេទ ដែលបានចែងនៅក្នុងច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ (**ច្បាប់ឆ្នាំ១៩៩៤**)[10]។ ច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ បានប្រកាសថា សមាជិកនៃក្រុមនេះជាអ្នករំលោភរដ្ឋធម្មនុញ្ញ ដែលរដ្ឋសភាជាតិប្រកាសឲ្យប្រើក្នុងឆ្នាំ១៩៩៤[11]។

ក្រុមមេធាវីការពារក្តីបានអះអាងថា ការព្រះរាជទានលើកលែងទោសលើលោក **អៀង សារី** គួរតែអាចបញ្ចប់ចំណាត់ការព្រហ្មទណ្ឌប្រឆាំងរូបគាត់។ ពួកគេបានបញ្ជាក់ទៀតថា អ.វ.ត.ក មានសមត្ថកិច្ចក្នុងការកំណត់អំពីវិសាលភាព ប៉ុន្តែមិនមានធម្មានុភាពទៅលើការព្រះរាជទានលើកលែងទោសនោះទេ។ យោងតាមសហមេធាវីការពារក្តីអន្តរជាតិ

លោក **កាណាវ៉ាស** បានលើកឡើងថា ច្បាប់ឆ្នាំ១៩៩៤ អនុវត្តទៅលើគ្រប់អំពើឧក្រិដ្ឋទាំងអស់ដែលខ្មែរក្រហមបានប្រព្រឹត្ត ពីឆ្នាំ១៩៧៥ ដល់ ១៩៧៩។ ហេតុដូចនេះ មានន័យថា វាបានគ្របដណ្តប់ទៅលើរាល់ការចោទប្រកាន់នានា នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

ចំណែកឯសហព្រះរាជអាជ្ញា បានបដិសេធទៅនឹងការបកស្រាយរបស់មេធាវីការពារក្តីអំពីសមត្ថកិច្ចរបស់ អ.វ.ត.ក ទាក់ទងនឹងការលើកលែងទោសនោះទេ ពីព្រោះការកំណត់របស់អង្គជំនុំជម្រះអំពីវិសាលភាពនៃការលើកលែងទោសចាំបាច់ត្រូវកំណត់អំពីសុពលភាពរបស់វា។ សហព្រះរាជអាជ្ញាបានបន្តទៀតថា មិនថាការលើកលែងទោសនេះមានវិសាលភាពប៉ុណ្ណានោះទេ ច្បាប់អន្តរជាតិមិនទទួលស្គាល់សុពលភាពនៃការលើកលែងទោសណាមួយចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដូចជាអំពើប្រល័យពូជសាសន៍ ដូច្នេះការលើកលែងទោសចំពោះលោក **អៀង សារី** មិនមានសុពលភាពនោះទេ[12]។

ក្រុមមេធាវីការពារក្តីបានធ្វើទឡ្ហីករណ៍តប ដោយលើកឡើងថា អ.វ.ត.ក ជាតុលាការក្នុងស្រុក[13]។ មេធាវីការពារក្តីបានទទូចថា កាតព្វកិច្ចអន្តរជាតិនៅកម្ពុជា មិនត្រូវឲ្យប៉ះពាល់ដល់ការបកស្រាយច្បាប់របស់តុលាការ ស្តីពីការលើកលែងទោស និងការអភ័យទោសនោះទេ[14]។ ក្រុមមេធាវីការពារក្តី បានលើកទឡ្ហីករណ៍ថា រដ្ឋមានសេរីភាពក្នុងការផ្តល់ការលើកលែងទោស សូម្បីតែឧក្រិដ្ឋកម្មដែលទទួលស្គាល់ដោយបទដ្ឋានអន្តរជាតិដាច់ខាតក៏ដោយ។ ពួកគេបានបន្តទៀតថា ទោះបីជាច្បាប់អន្តរជាតិហាមឃាត់ការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ក៏មិនមានកាតព្វកិច្ចណាមួយ ដែលរដ្ឋត្រូវតែកាត់ទោសជនដៃដល់ដែរ[15]។

### គ. អាជ្ញាយុកាលក្រោមច្បាប់កម្ពុជា

បញ្ហាទីបីត្រូវបានលើឡើងនៅក្នុងអំឡុងពេលសវនាការ គឺការពិចារណាថាតើអាជ្ញាយុកាលអាចហាមឃាត់ការកាត់ទោសទៅលើឧក្រិដ្ឋកម្មមួយចំនួនស្ថិតក្រោមច្បាប់ព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ដែរឬទេ។

#### ១. តើការកាត់ទោសទៅលើឧក្រិដ្ឋកម្មថ្នាក់ជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ មានការរារាំងដោយពេលវេលាដែរឬទេ?

ជនជាប់ចោទទាំងបួនរូប ត្រូវបានរងការចោទប្រកាន់ទាក់ទងនឹងបទល្មើសអន្តរជាតិ និងឧក្រិដ្ឋកម្មស្ថិតក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ រួមមាន មនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា ។ អាជ្ញាយុកាល

នៃបទល្មើសថ្នាក់ជាតិ មានរយៈពេល១០ឆ្នាំ ដែលមានចែងនៅក្នុងច្បាប់កម្ពុជា (ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៦៤ និង ច្បាប់អ៊ុនតាក់ឆ្នាំ១៩៩២)[16] ប៉ុន្តែច្បាប់ អ.វ.ត.ក ឆ្នាំ២០០១ និងវិសោធនកម្មច្បាប់ អ.វ.ត.ក ឆ្នាំ២០០៤[17] បានបង្កើនរយៈពេលដល់ ២០ឆ្នាំ និង ៣០ឆ្នាំ។ គួរកត់សម្គាល់ផងដែរថា ក្រមនីតិវិធីព្រហ្មទណ្ឌដែលត្រូវ បានអនុម័តក្នុងឆ្នាំ២០០៧ អាជ្ញាយុកាលនៃបទល្មើសត្រូវបានកំណត់រយៈពេល ១៥ឆ្នាំ និងពុំមានកំណត់អាជ្ញាយុកាលទេចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមឡើយ។

មុនសវនាការបឋម មេធាវីការពារក្តីទាំងបួនក្រុមបានដាក់ការជំទាស់មួយចំនួន ដោយលើកឡើងអំពីបញ្ហាអាជ្ញាយុកាល ក្នុងការកាត់ទោសឧក្រិដ្ឋកម្មក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦។ ក្រុមមេធាវីលោក **អៀង សារី** ក៏បានជំទាស់ផងដែរនឹងការកាត់ទោសពីបទបំពារបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដោយបានអះអាងថា អាជ្ញាយុកាលក្នុងស្រុក ក៏ត្រូវអនុវត្តទៅលើឧក្រិដ្ឋកម្មអន្តរជាតិទាំងនេះផងដែរ ដោយសារតែ អ.វ.ត.ក មានលក្ខណៈជាតុលាការកូនកាត់។ ដូច្នេះហើយ មានការចោទជាសំណួរដូចខាងក្រោម នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ៖ (១) តើអាជ្ញាយុកាលស្ថិតក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ អនុវត្តទៅលើឧក្រិដ្ឋកម្មក្នុងស្រុកដែលត្រូវកាត់សេចក្តីនៅចំពោះមុខ អ.វ.ត.ក ឬអនុវត្តទៅលើការបំពារបំពានធ្ងន់ធ្ងរចំពោះអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩? ប្រសិនបើអនុវត្ត (២) តើរយៈពេលដែលបានកំណត់ ១០ឆ្នាំ សម្រាប់ការកាត់ទោសឧក្រិដ្ឋកម្មទាំងនេះ ផុតកំណត់នៅមុនឆ្នាំ២០០១ ឬត្រូវពន្យារពេល? (៣) តើជាការស្របច្បាប់ដែរឬទេក្នុងការ ពន្យារអាជ្ញាយុកាលឡើងវិញ បើអាជ្ញាយុកាលចាស់ផុតរលត់នៅក្រោមច្បាប់ក្នុងស្រុក? ភាគីបានបង្ហាញទឡ្ហីករណ៍ដោយផ្ទាល់មាត់ ដោយយោងទៅដល់ការសម្រេចចិត្តទៅលើបញ្ហានេះដោយអង្គជំនុំជម្រះសាលាដំបូងក្នុងករណីសំណុំរឿង០០១[18] និងអង្គបុរេជំនុំជម្រះក្នុងសំណុំរឿង០០២[19]។

### ២. សេចក្តីសម្រេចពីមុនលើអាជ្ញាយុកាលនៃបទល្មើសថ្នាក់ជាតិ

បញ្ហានៃភាពអាចអនុវត្តបានទាក់ទងនឹងអាជ្ញាយុកាលនៃបទល្មើស ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ត្រូវបានគេលើកឡើងដំបូងក្នុងករណីសំណុំរឿង០០១ ដោយមេធាវីរបស់លោក **កាំង ហ្គេចអ៊ាវ** ហៅ “**ឌុច**” លើកទឡ្ហីករណ៍ថា អ.វ.ត.ក មិនមានយុត្តាធិការទៅលើបទល្មើសក្នុងស្រុកទេ ដោយសារតែអាជ្ញាយុកាលបានផុតទៅហើយ[20]។ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើសេចក្តីជំទាស់នេះ ដោយមានការយល់ឃើញពីរដាច់ដោយឡែកពីគ្នាអំពីសុពលភាពនៃអាជ្ញាយុកាល។ នៅក្នុងឆ្នាំ២០០១ ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានអះអាងបញ្ជាក់អំពីធម្មនុញ្ញភាពនៃការបង្កើនអាជ្ញាយុកាលសម្រាប់ឧក្រិដ្ឋកម្មក្នុងស្រុកក្រោមមាត្រា៣ (ថ្មី) នៃច្បាប់ អ.វ.ត.ក[21]។

យោងតាមស្ថានភាពនេះ ចៅក្រមកម្ពុជានៃសាលាដំបូង បានលើកឡើងថា អាជ្ញាយុកាលមិនបានផុតរលត់នោះទេ។ ប៉ុន្តែចៅក្រមអន្តរជាតិបានបញ្ចេញទស្សនៈថា ការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មក្នុងស្រុកទាក់ទងនឹងអំពើឃាតកម្ម និងអំពើទារុណកម្ម ត្រូវបានរលត់ហើយ ពីព្រោះរយៈពេលកំណត់ ១០ឆ្នាំ ក្រោមច្បាប់កម្ពុជាបានផុតកំណត់ ខណៈពេលដែលច្បាប់ អ.វ.ត.ក បែរជាពង្រីកវិសាលភាពអាជ្ញាយុកាលរបស់ខ្លួន។ ដោយសារតែអង្គជំនុំជម្រះសាលាដំបូង ពុំអាចស្វែងរកមតិស្របគ្នា ថាតើបទចោទប្រកាន់ក្នុងស្រុកមានសុពលភាព ឬពុំមានសុពលភាពនោះ អង្គជំនុំជម្រះសាលាដំបូងមិនបានវិនិច្ឆ័យទៅលើពិរុទ្ធិភាព ឬពុំមានពិរុទ្ធិភាពទៅលើជនជាប់ចោទទាក់ទងនឹងបទចោទប្រកាន់ថ្នាក់ជាតិទេ។ នៅក្នុងសាលក្រមសំណុំរឿង០០១ ចុះកាលបរិច្ឆេទថ្ងៃទី២៦ កក្កដា ២០១០ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងយ៉ាងសាមញ្ញថា ទាក់ទងនឹងពិរុទ្ធិភាពរបស់ **ឌុច** ចំពោះអំពើមនុស្សឃាត និងទារុណកម្មស្ថិតក្រោមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ អង្គជំនុំជម្រះសាលាដំបូងមិនបានវាយតម្លៃទេ[22]។

នៅពេលដែលបញ្ហានេះកើតឡើងម្តងទៀតក្នុងករណីសំណុំរឿង០០២ អង្គបុរេជំនុំជម្រះ បានសម្រេចយកគោលជំហររបស់ចៅក្រមកម្ពុជាដែលបានចាប់យកនៅក្នុងសំណុំរឿង០០១ ព្រមទាំងបានសម្រេចថា អាជ្ញាយុកាល ១០ឆ្នាំ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ បានចាប់ផ្តើមរាប់ចាប់ពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ (នៅពេលចាប់ផ្តើមសម័យអ៊ុនតាក់) ដូច្នេះ អាជ្ញាយុកាល មិនទាន់ផុតកំណត់នៅក្នុងឆ្នាំ២០០១ទេ[23]។ ជាលទ្ធផល ច្បាប់ អ.វ.ត.ក ឆ្នាំ២០០១ (វិសោធនកម្មក្នុងឆ្នាំ២០០៤) មានសុពលភាពពន្យាររយៈពេលកំណត់ ដូច្នេះឧក្រិដ្ឋកម្មក្នុងស្រុកដែលបានចោទប្រកាន់ទៅលើជនជាប់ចោទទាំងបួន មិនទាន់ផុតកំណត់ទេ។

## ៣. ទឡ្ហីករណ៍របស់ភាគី ស្តីពីអាជ្ញាយុកាលនៃបទល្មើសថ្នាក់ជាតិ

ក្នុងអំឡុងពេលតទល់គ្នានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង កាលពីខែមិថុនា ឆ្នាំ២០១១ សហមេធាវីការពារក្តី បានជំទាស់នឹងការគណនារបស់អង្គបុរេជំនុំជម្រះអំពីរយៈពេលដែលអាជ្ញាយុកាលចាប់ផ្តើមរាប់។ ការដួលរលំនៃរបបខ្មែរក្រហម គឺជាកាលបរិច្ឆេទចាប់ផ្តើមគិតអំពីអាជ្ញាយុកាល។ មេធាវីការពារក្តីបានបន្ថែមទៀតថា តាមពិតអាជ្ញាយុកាលនៃបទល្មើសថ្នាក់ជាតិ បានផុតកំណត់តាំងពីឆ្នាំ១៩៨៩ ។ យោងតាមទិដ្ឋភាពនេះ ប្រតិសកម្មនៃច្បាប់ដែលមានចែងនៅក្នុងមាត្រា៣ នៃច្បាប់ អ.វ.ត.ក បានរំលោភទៅលើគោលការណ៍នីត្យានុកូលភាព និងការកាត់ទោសបទឧក្រិដ្ឋថ្នាក់ជាតិ រួមមាន មនុស្សឃាត ទារុណកម្ម និងការធ្វើទុក្ខបុកម្នេញផ្នែកសាសនា គួរតែត្រូវបានហាមឃាត់។ សហមេធាវីការពារក្តីបានបន្តលើកទឡ្ហីករណ៍ថា ការពន្យារអាជ្ញាយុកាលនៃបទឧក្រិដ្ឋថ្នាក់ជាតិ គឺដើម្បីតែការកាត់ទោសនៅ អ.វ.ត.ក ហើយ

មិនបានអនុវត្តនៅតុលាការក្នុងស្រុកទេ ដែលនេះរំលោភលើគោលការណ៍សមភាពចំពោះមុខច្បាប់។ ប៉ុន្តែ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ឧក្រិដ្ឋកម្មថ្នាក់ជាតិនៅតែស្ថិតក្នុងដែនយុត្តាធិការនៃ អ.វ.ត.ក ហើយវាមិនប៉ះពាល់ដល់យុត្តាធិការបុគ្គលឡើយ ឬអាចនិយាយម្យ៉ាងទៀតថា ការមិនអនុវត្តអាជ្ញាយុកាលនៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ គឺមិនពាក់ព័ន្ធសមាសភាពជនជាប់ចោទទេ ឲ្យតែជននោះស្ថិតក្នុងរង្វង់យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

សហព្រះរាជអាជ្ញា បានគាំទ្រនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ និងបានលើកទឡ្ហីករណ៍ថា អាជ្ញាយុកាលមិនចាប់រាប់ទេក្នុងអំឡុងឆ្នាំ១៩៧៩ ដល់ ១៩៩២ ។ សហព្រះរាជអាជ្ញាបានពន្យល់ថា ទោះបីជាអាជ្ញាយុកាលចាប់រាប់តាំងពីឆ្នាំ១៩៧៩ ដល់ ១៩៩២ ក៏ដោយ ក៏ការកំណត់រយៈពេលនេះត្រូវរំកិល ឬពន្យារក្នុងរយៈពេលនោះដែរ ដោយសារតែប្រទេសកម្ពុជាកំពុងស្ថិតនៅក្នុងស្ថានភាពសង្គ្រាមស៊ីវិល និងពុំមានប្រព័ន្ធតុលាការប្រព្រឹត្តទៅត្រឹមត្រូវនោះទេ។ រហូតមកទល់នឹងឆ្នាំ១៩៩២ ទើបប្រទេសកម្ពុជាចាប់ផ្តើមកកើតឡើងវិញនូវប្រព័ន្ធយុត្តិធម៌ ដូចជា គណៈមេធាវី ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងរចនាសម្ព័ន្ធតុលាការ។ ដើម្បីគាំទ្រនូវគោលគំនិតរបស់ខ្លួន សហព្រះរាជអាជ្ញាបានលើកឡើងនូវយុត្តិសាស្ត្រអន្តរជាតិ ក្នុងការរំកិលអាជ្ញាយុកាលនៅក្នុងអំឡុងពេលសង្គ្រាម ដូចជា ក្នុងប្រទេសអាឡឺម៉ង់ បារាំង និងសហរដ្ឋអាមេរិក។ សហព្រះរាជអាជ្ញា ក៏បានពឹងផ្អែកផងដែរទៅលើគោលការណ៍អន្តរជាតិទូទៅ ដែលជាប់ទាក់ទឹងនឹងជម្លោះប្រដាប់អាវុធ។ ជាចុងក្រោយ សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា ជនជាប់ចោទមិនគួរទទួលប្រយោជន៍ពីអាជ្ញាយុកាល ដែលបណ្តាលមកពីអំពើរបស់ខ្លួនធ្វើឲ្យប្រទេសស្ថិតក្នុងស្ថានភាពសង្គ្រាមស៊ីវិលនោះទេ។ អ្នកទាំងនេះគួរត្រូវហាមឃាត់មិនឲ្យលើកឡើអំងពីបញ្ហាអាជ្ញាយុកាល ដូចខ្លឹមសារច្បាប់ចែងថា "ពុំមានការជំនុំជម្រះទៅលើអំពើ ដែលជាកំហុសរបស់ខ្លួនឡើយ"[24] ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានគាំទ្រជាមួយនឹងទឡ្ហីករណ៍របស់ភាគីព្រះរាជាអាជ្ញា។

***<u>កំណត់សម្គាល់</u>*** ៖ នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី២២ កញ្ញា ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ការកាត់ទោសលើបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មិនអាចដំណើរការបានទេ ដោយសារតែនៅក្នុងដីកាដំណោះស្រាយពុំមានបន្ទុកគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ ក្នុងនោះរួមមាន កង្វះខាតនៃអង្គហេតុជាក់លាក់។ សេចក្តីសម្រេចនេះ មិនបានលើកឡើងអំពីបញ្ហាអាជ្ញាយុកាលនៃបទល្មើសថ្នាក់ជាតិឡើយ ប៉ុន្តែវាហាក់ដូចជាយោងទៅលើទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងសវនាការបឋមកាលពីខែមិថុនា។

### ឃ. អាជ្ញាយុកាលនៃការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ

ដូចបានលើកឡើង ជនជាប់ចោទមួយរូប បានជំទាស់ ទៅនឹងអាជ្ញាយុកាលនៃការរំលោភបំពានទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ដោយលើកទឡ្ហីករណ៍ថា អាជ្ញាយុកាលបានអនុវត្តហួសពីការកំណត់នៅក្នុងច្បាប់ជាតិ។ ដំបូងការជំទាស់របស់លោក **អៀង សារី** បានអះអាងថា អាជ្ញាយុកាល ១០ឆ្នាំ ក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ក៏ត្រូវអនុវត្តចំពោះការរំលោភបំពានធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ដែរ ដូច្នេះគាត់មិនគួរត្រូវបានកាត់ទោសទៅលើបទចោទប្រកាន់ទាំងឡាយដែលមាននៅក្នុងដីកាដំណោះស្រាយនោះទេ។ ក្រុមមេធាវីការពារក្តីលោក **អៀង សារី** បានលើកទឡ្ហីករណ៍ដោយសំអាងថា មាត្រា៦ នៃច្បាប់ អ.វ.ត.ក ពុំមានចែងពី "អាជ្ញាយុកាល" នោះទេ ដែលខុសប្លែកពីមាត្រានានាស្តីពីអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ យោងតាមក្រុមមេធាវីការពារក្តី ភាពស្រពិចស្រពិលនៃច្បាប់គួរតែបានជាប្រយោជន៍ដល់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យ[25]ភាគីបកស្រាយទៅលើសំណួរពីរដូចខាងក្រោម ដើម្បីជាជំនួយដល់អង្គជំនុំជម្រះនៅក្នុងការដោះស្រាយបញ្ហាដែលលើកឡើង ។

### ***១. តើច្បាប់ទំនៀមទំលាប់អន្តរជាតិ ឆ្នាំ១៩៧៥ -១៩៧៩ បានលើកឡើង និងអនុញ្ញាតឲ្យអនុវត្តអាជ្ញាយុកាលទៅលើការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ដែរឬទេ?***

មេធាវីការពារក្តីរបស់ជនជាប់ចោទ **អៀង សារី** បានបង្ហាញថា មិនមានមាត្រាណាមួយនៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ បញ្ជាក់អំពីការហាមឃាត់ការអនុវត្តអាជ្ញាយុកាលនោះទេ ក៏ប៉ុន្តែសហព្រះរាជអាជ្ញាបានជំទាស់ទៅវិញថា រដ្ឋមានកាតព្វកិច្ចពេញលេញក្នុងការកាត់ទោសបុគ្គលដែលមានទំនួលខុសត្រូវចំពោះការប្រព្រឹត្តអំពើរំលោភបំពានទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩។ សហព្រះរាជអាជ្ញា បានលើកហេតុផលថា ស្ថិតក្រោមអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ រដ្ឋមិនអាចរីតត្បិតការទទួលខុសត្រូវរបស់ខ្លួនជាឯកតោភាគីនោះទេ ដោយការអនុវត្តន៍អាជ្ញាយុកាល។ សហព្រះរាជអជ្ញាបានលើកទឡ្ហីករណ៍បន្ថែមទៀតថា នៅក្នុងឆ្នាំ១៩៧៥ ការហាមឃាត់ទៅលើការរំលោភបំពានធ្ងន់ធ្ងរនេះ បានក្លាយជាបទដ្ឋានដាច់ខាតមួយ ដែលមានន័យថា បដិប្បញ្ញត្តិ មិនត្រូវអនុញ្ញាតិឲ្យកើតមានឡើយ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានគូសបញ្ជាក់ថា មិនមានអនុសញ្ញាអន្តរជាតិណាផ្សេងទៀត ដែលមានឋានៈដូចនឹងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ទេ នៅដើមឆ្នាំ១៩៧៥ អនុសញ្ញានេះត្រូវបានគេអនុម័តដោយគ្មានលក្ខខណ្ឌដោយរដ្ឋចំនួន១៣៣ ក្នុងចំណោមរដ្ឋទាំង១៣៨ នៃអង្គការសហប្រជាជាតិ រួមបញ្ចូលទាំងសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខទាំងអស់ ព្រមទាំងកម្ពុជាផងដែរ[26]។ ផ្ទុយទៅវិញ មេធាវី **កាណាវ៉ាស** បានអះអាងថា ការមិនកំណត់អាជ្ញាយុកាលនៃឧក្រិដ្ឋកម្មសង្គ្រាម ពុំស្ថិតនៅក្នុងច្បាប់ទំនៀមទំលាប់អន្តរជាតិឆ្នាំ១៩៧៥នោះទេ។ គាត់បានស្នើឡើងថា អនុសញ្ញាឆ្នាំ១៩៦៨ ស្តីពី ភាពពុំអាចអនុវត្តបាននៃអាជ្ញាយុកាលទៅលើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ត្រូវបានអនុម័តដោយរដ្ឋចំនួនតែ ១៧ ប៉ុណ្ណោះនាពេលនោះ ហើយប្រទេសកម្ពុជាមិនស្ថិតក្នុងចំណោមរដ្ឋនោះទេ។ ដូច្នេះ ប្រទេសកម្ពុជានៅតែមិនមែនជារដ្ឋភាគីនៃអនុសញ្ញានោះ[27]។

***ង. តើមាត្រា៦ នៃវិសោធនកម្មច្បាប់ អ.វ.ត.ក បានកំណត់ពីការរំលោភបំពានធ្ងន់ធ្ងរ គឺជាបទឧក្រិដ្ឋ ដូចមានចែងក្នុងអនុសញ្ញាទីក្រុងហ្សឺណែវដែរឬទេ ឬតើថាមានការអនុវត្តន៍បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញាទីក្រុងហ្សឺណែវ?***

មេធាវីការពារក្តីលោក **អៀង សារី** បានធ្វើការបកស្រាយក្នុងន័យចង្អៀតទៅលើមាត្រា៦ នៃវិសោធនកម្មច្បាប់ អ.វ.ត.ក ដោយបានចង្អុរបង្ហាញថា បទបញ្ញត្តិនេះពុំបានអនុវត្តលើមាត្រាទាំងឡាយនៃអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ នោះទេ។ សហព្រះរាជអាជ្ញាបានឈរលើគោលជំហរផ្ទុយពីនេះ ដោយបានលើកឡើងថា ច្បាប់ អ.វ.ត.ក គឺជាច្បាប់ដែលផ្តល់យុត្តាធិការទៅលើតែបទឧក្រិដ្ឋមួយចំនួននៅ អ.វ.ត.ក ហើយច្បាប់ អ.វ.ត.ក មិនមែនជាច្បាប់ជាតិក្នុងការកំណត់នូវបទឧក្រិដ្ឋនោះទេ[28]។ ផ្អែកតាមន័យនេះ ចៅក្រមត្រូវបានតម្រូវឲ្យយោងទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ មិនត្រឹមតែការកំណត់នូវបទល្មើស និងធាតុផ្សំរបស់វាប៉ុណ្ណោះទេ ថែមទាំងការចេញនូវសេចក្តីសម្រេច នានា ដូចជា បញ្ហាទាក់ទងនឹងការអនុវត្តន៍អាជ្ញាយុកាល ប្រសិនបើមានចោទឡើង។

**ឃ. សិទ្ធិរបស់ជនជាប់ចោទក្នុងការលះបង់សិទ្ធិមិនចូលរួមនៅក្នុងសវនាការ**

ការលះបង់សិទ្ធិមិនចូលរួមសវនាការ គឺជាចំណោទបញ្ហាចុងក្រោយ ដែលត្រូវបានលើកយកមកពិភាក្សាក្នុងអំឡុងសវនាការបឋម តើសិទ្ធិរបស់ជនជាប់ចោទត្រូវតែចូលរួមតាមដានសវនាការ ឬត្រូវអវត្តមាន។ បញ្ហាសុខភាព គឺជាចំណោទចម្បងមួយដែលបណ្តាលឲ្យជនជាប់ចោទអវត្តមានពីដំណើរការសវនាការ ក្នុងនោះជនជាប់ចោទបីរូបបានជំទាស់ទៅលើការចូលរួមសវនាការដោយសារបញ្ហាកាយសម្បទា រួមមាន លោកស្រី **អៀង ធីរិទ្ធ** លោក **អៀង សារី** និង លោក **នួន ជា**។ នៅក្នុងសវនាការបឋមបួនថ្ងៃនេះ ជនជាប់ចោទគ្រប់រូបបានស្នើសុំមិនចូលរួមនៅក្នុងបន្ទប់សវនាការស្ទើរតែគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធី។ ខណៈនៅពេលមួយ មេធាវីការពារក្តីលោក **ខៀវ សំផន** បានស្នើសុំអង្គជំនុំជម្រះអនុញ្ញាតិឲ្យកូនក្តីរបស់ខ្លួនចាកចេញពីបន្ទប់សវនាការ ពីព្រោះគាត់ហត់នឿយអស់កម្លាំង ពិបាកក្នុងការតាមដានសវនាការ តែខ្លួនដែលជាមធាវីការពារក្តីនឹងមានវត្តមាននៅគ្រប់ដំណាក់កាល ។ អង្គជំនុំជម្រះសាលាដំបូង បានពិនិត្យឃើញថា លក្ខខណ្ឌសុខភាពរបស់លោក **ខៀវ សំផន** ដូចជាមិនដុនដាប ឬធ្ងន់ធ្ងរនោះទេ។ បញ្ហានេះបានឈានទៅដល់ការពិភាក្សាមួយ ថាតើជនជាប់ចោទអាចលះបង់សិទ្ធិចូលរួម ឬមិនចូលរួមសវនាការដោយផ្ទាល់បានដែរឬទេ ។

ជាទូទៅ ជនជាប់ចោទគឺតម្រូវឲ្យមានវត្តមាននៅក្នុងអំឡុងពេលនៃការជំនុំជម្រះទៅលើករណីរបស់ខ្លួន ហើយចៅក្រមមានសិទ្ធិអំណាចក្នុងការកំណត់ឲ្យជនចោទចោទមានវត្តមាននៅក្នុងដំណើរការនីតិវិធី[29]។ ទោះបីជាយ៉ាងណា វិធានផ្ទៃក្នុងបានផ្តល់នូវករណីលើកលែងមួយចំនួន ដូចជា នៅពេលដែលជនជាប់ចោទអវត្តមានដោយបញ្ហាសុខភាព និងបញ្ហាធ្ងន់ធ្ងរផ្សេងៗទៀត។ នៅក្នុងករណីលើកលែងទាំងនេះ អង្គជំនុំជម្រះសាលាដំបូង អាចនៅតែបន្តដំណើរការនីតិវិធីដោយមិនមានវត្តមានរបស់ជនជាប់ចោទ ប៉ុន្តែតម្រូវឲ្យមានការយល់ព្រមពីជនជាប់ចោទ ឬជនជាប់ចោទអាចចូលរួមតាមមធ្យោបាយសោតទស្សន៍សមស្រប។

### ក. ទស្សនៈពីភាគី

ខណៈពេលដែលអង្គជំនុំជម្រះកំពុងតែប្រឈមនឹងការរកដំណោះស្រាយទៅលើសំណើរបស់លោក **ខៀវ សំផន** ចំពោះការលះបង់សិទ្ធិមិនចូលរួមសវនាការដោយសារតែភាពនឿយហត់អស់កម្លាំង ហើយម្យ៉ាង ជនជាប់ចោទមានតំណាងមេធាវីស្របច្បាប់នៅចំពោះមុខអង្គសវនាការ លោកមេធាវី **កាណាវ៉ាស** ដែលជាមេធាវីការពារក្តីឲ្យលោក **អៀង សារី** ក៏បានស្នើសុំអង្គជំនុំជម្រះដូចគ្នាផងដែរ គឺកូនក្តីរបស់លោកសុំលះបង់សិទ្ធិមិនចូលរួមសវនាការ។ **កាណាវ៉ាស** បានលើកឡើងថា ការបង្ខំឲ្យជនជាប់ចោទនៅតែចូលរួមតាមដានសវនាការ ខណៈពេលដែលគាត់មិនមានឆន្ទៈចូលរួម នោះគឺជាការរំលោភសិទ្ធិក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងសិទ្ធិមនុស្សរបស់ជនជាប់ចោទ។ មេធាវី **កាណាវ៉ាស** ក៏បានបង្ហាញថា នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ដែលគាត់ធ្លាប់ធ្វើការ ជនជាប់ចោទដែលមិនមានឆន្ទៈចូលរួមសវនាការលើករណីរបស់ខ្លួន គឺត្រូវបានគេអនុញ្ញាត ហើយជនជាប់ចោទរូបនោះអាចត្រឡប់ទៅមន្ទីរឃុំឃាំងវិញ ទោះបីជាគ្មានការតភ្ជាប់នូវបច្ចេកទេសសោតទស្សន៍ក៏ដោយ។ ដើម្បីជម្រុញឲ្យអង្គជំនុំជម្រះសម្រេចអនុញ្ញាតឲ្យកូនក្តីរបស់ខ្លួនអាចអវត្តមានពីបន្ទប់សវនាការ មេធាវី **កាណាវ៉ាស** បានស្នើឡើងថា ជនជាប់ចោទអាចប្រគល់ជូននូវលិខិតលះបង់សិទ្ធិមិនចូលរួមសវនាការ ដែលជូនភ្ជាប់ហត្ថលេខារបស់ជនជាប់ចោទ។ ការធ្វើបែបនេះ លោក **អៀង សារី** នឹងមិនអាចទាមទារថា គាត់មិនបានទទួលនូវការជំនុំជម្រះដោយត្រឹមត្រូវតាមច្បាប់នោះទេ។

លោក **ខេយលី** បានឯកភាពថា ជនជាប់ចោទគួរតែដាក់លិខិតលះបង់សិទ្ធិជាលាយលក្ខណ៍អក្សរដោយមានចុះហត្ថលេខា និងមានបញ្ជាក់ឲ្យបានច្បាស់អំពីហេតុផលដែលពួកគេមិនចូលរួមក្នុងដំណើរការនីតិវិធី នាថ្ងៃនីមួយៗ។ គាត់បានបញ្ជាក់បន្ថែមថា ទោះបីជាតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ពិតជាបានអនុញ្ញាតិឲ្យអវត្តរបស់ជនជាប់ចោទក៏ដោយ ក៏មិនមានន័យថា ជនជាប់ចោទមិនយកចិត្តទុកដាក់ចំពោះការចូលរួមសវនាការដែរ។

លោក **ខេយលី** បានរំលឹកដល់តុលាការថា តម្រូវការជាមូលដ្ឋាននៅគ្រប់យុត្តាធិការថ្នាក់ជាតិ និងអន្តរជាតិ វត្តមានរបស់ជនជាប់ចោទ គឺតម្រូវឲ្យមាននៅក្នុងសវនាការ។ លោកសហព្រះរាជអាជ្ញាស្នើថា អង្គជំនុំជម្រះសាលាដំបូងគួរតែតែងតាំងនូវអ្នកជំនាញធ្វើការពិនិត្យ ថាតើជនជាប់ចោទពិតជាមិនអាចចូលរួមសវនាការ ដោយសារតែបញ្ហាសុខភាពរូបកាយ ឬស្មារតី។

### ខ. សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

បន្ទាប់ពីភាគីបញ្ចប់នូវទឡ្ហីករណ៍របស់ខ្លួន ចៅក្រម **ឡាវេង** បានបញ្ជាក់ថា វិធាន៨១ នៃវិធានផ្ទៃក្នុង បានផ្តល់នូវលទ្ធភាព (សេណារីយ៉ូ) ពីរយ៉ាង ដែលជនជាប់ចោទអាចអវត្តមានពីដំណើរការនីតិវិធី ហើយករណីនេះមិនត្រូវភ័ន្តច្រឡំនោះទេ។ នៅក្នុងសេណារីយ៉ូទីមួយ ជនជាប់ចោទមិនបង្ហាញខ្លួន ដោយលះបង់សិទ្ធិក្នុងការមិនចូលរួមតាមដានសវនាការ ប៉ុន្តែមានវត្តមានមេធាវីរបស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ ចំណែកឯសេណារីយ៉ូទីពីរ ជនជាប់ចោទមានឆន្ទៈក្នុងការចូលរួមសវនាការ ប៉ុន្តែមិនអាចធ្វើទៅកើត ដោយសារតែមូលហេតុសុខភាព ឬមូលហេតុធ្ងន់ធ្ងរដទៃទៀត ដូចនេះជំនួសដោយការចូលរួមពីចម្ងាយតាមរយៈមធ្យោយសោតទស្សន៍ពីបន្ទប់ឃុំឃាំង។ លទ្ធភាពនេះអនុវត្តបានតែនៅពេលដែលក្រុមមេធាវីការពារក្តីរបស់ជនជាប់ចោទ ជូនដំណឹងជាមុនដល់អង្គជំនុំជម្រះអំពីកាលៈទេសៈទាក់ទងនឹងអវត្តមានរបស់ជនជាប់ចោទ ក្នុងគោលបំណងដើម្បីឲ្យអង្គជំនុំជម្រះធ្វើការកំណត់ និងសម្រេចទៅលើសំណូមពរនោះ។ ចៅក្រម **និល ណុន** បានបញ្ជាក់សារជាថ្មីថា ការអនុញ្ញាតនេះនឹងផ្តល់ឲ្យសម្រាប់តែមួយថ្ងៃៗប៉ុណ្ណោះ ដូច្នេះ ជនជាប់ចោទត្រូវតែបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះជារៀងរាល់ថ្ងៃ ។

បន្ទាប់មក អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យលោក **អៀង សារី** ចូលរួមតាមដានសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោទស្សន៍នៅក្នុងបន្ទប់រងចាំ ដោយសារតែភាពដុនដាបនៃជំងឺខ្នងរបស់គាត់។ ប៉ុន្តែ អង្គជំនុំជម្រះបានបដិសេធចោលនូវសំណូមពររបស់លោក **ខៀវ សំផន** ដែលបានស្នើសុំផ្អែកលើហេតុផលនឿយហត់អស់កម្លាំង ព្រមទាំងបង្គាប់ឲ្យគាត់បន្តការចូលរួមនៅក្នុងបន្ទប់សវនាការ។

## III. **ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

នៅក្នុងសេចក្តីសម្រេចថ្ងៃទី២៤ មិថុនា ២០១១ ដែលបានប្រកាសប៉ុន្មានថ្ងៃមុនពេលសវនាការបឋមចាប់ផ្តើម អង្គបុរេជំនុំជម្រះបានសម្រេចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១,៧២៨ រូប ដែលបាន

ប្ដឹងជំទាស់ចំពោះការបដិសេធមិនបញ្ចូលជាភាគីដើមបណ្ដឹងនៅក្នុងសំណុំរឿង០០២។ យោងតាមអង្គបុរេជំនុំជម្រះ គឺថា សហចៅក្រមស៊ើបអង្កេតបានធ្វើការបកស្រាយច្បាប់ក្នុងន័យចង្អៀត អំពីលក្ខខណ្ឌវិនិច្ឆ័យនៃព្យសនកម្មចាំបាច់ក្នុងការទទួលស្គាល់ជាជនរងគ្រោះ។ លើសពីនេះទៀត អង្គបុរេជំនុំជម្រះបានលើកឡើងថា ការបើកទូលាយនូវការទទួលយកការដាក់ពាក្យសុំតាំងខ្លួនជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿងឧក្រិដ្ឋកម្មអន្តរជាតិធ្ងន់ធ្ងរ ដូចជា អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ មានភាពខុសប្លែកគ្នាពីការអនុវត្តន៍នៅក្នុងតុលាការក្នុងស្រុកទាក់ទងនឹងបទល្មើសជាតិ។ សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ធ្វើឲ្យចំនួនដើមបណ្ដឹងរដ្ឋប្បវេណីកើនឡើងស្ទើរទ្វេរដង រហូតដល់ជិត ៤,០០០ នាក់។

### ក. ការពន្យារពេលកំណត់សម្រាប់សហមេធាវីដាក់បញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានសំណូមពរបន្ថែមរយៈពេល ២ខែ ក្នុងការដាក់បញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណីថ្មី ដោយសារតែចំនួនដើមបណ្ដឹងរដ្ឋប្បវេណីមានការកើនឡើងយ៉ាងច្រើននៅក្នុងសំណុំរឿង០០២។ មេធាវីនាំមុខ បានពន្យល់ថា ការពន្យារពេលនេះ គឺជាការចាំបាច់ ពីព្រោះពួកគេត្រូវការពេលវេលាក្នុងការកំណត់ថាបុគ្គលណាអាចឡើងបង្ហាញភស្តុតាង និងម្យ៉ាងទៀត បញ្ជីកែប្រែនេះនឹងកំណត់ពីដើមបណ្ដឹងរដ្ឋប្បវេណីរូបណាត្រូវផ្ដល់ព័ត៌មានចាំបាច់ទាក់ទងនឹងអង្គហេតុទាំងបួនដែលត្រូវធ្វើសវនាការដំបូង។ សហមេធាវីនាំមុខ បានលើកសំអាងថា នេះគឺជាតួនាទីរបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការទទួលខុសត្រូវរៀបចំកាត់បន្ថយបញ្ជីឈ្មោះកូនក្តីរបស់ខ្លួន យោងតាមវិធាន៨០ មិនមែនជាអង្គជំនុំជម្រះនោះទេ។ សហមេធាវីនាំមុខ បានឯកភាពថា វិធាន៨០ បានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូង គឺទទួលខុសត្រូវក្នុងការកាត់បន្ថយបញ្ជីឈ្មោះរបស់សាក្សី និងសាក្សីជំនាញ។ តែទោះបីជាយ៉ាងណា មេធាវីនាំមុខ បានលើកសំអាងថា វិធាននេះមិនបានកំណត់អំពីដើមបណ្ដឹងរដ្ឋប្បវេណីនោះទេ ហេតុដូចនេះ ការងារនេះគួរតែទុកឲ្យសហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាអ្នករៀបចំ។

### ខ. ការកំណត់អំពីទម្រង់នៃការទាមទារដំបូង

វិធាន២៣ ដែលបានធ្វើវិសោធនកម្ម ចែងថា ដើមបណ្ដឹងរដ្ឋប្បវេណីអាចទាមទារសំណងពីរប្រភេទ ៖ ទីមួយ គឺស្ថិតក្នុងទម្រង់នៃការទាមទារសំណងរដ្ឋប្បវេណីពីជនជាប់ចោទ ប្រសិនបើជនជាប់ចោទត្រូវទទួលការផ្ដន្ទាទោស និងទីពីរ គឺតាមទម្រង់ផ្តួចផ្តើមនូវសំណង ដោយការជួយសម្រួលពីអង្គភាពគាំពារជនរងគ្រោះ ប៉ុន្តែប្រភពហិរញ្ញវត្ថុត្រូវស្វែងរកពីខាងក្រៅ។ ទម្រង់ទីពីរនេះ ត្រូវបានចែងបញ្ចូលទៅក្នុងវិធាន ១២ស្ទួន(២) និង (៣) នៃវិធានផ្ទៃក្នុងវិសោធនកម្ម

លើកទី៦[30]។ ទោះជាយ៉ាងណា ក៏គ្រប់ទម្រង់នៃសំណងសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី នៅតែមានលក្ខណៈ "សមូហភាព និងផ្លូវចិត្ត" និងមានលក្ខណៈជានិមិត្តរូប។

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលោក **ពេជ្រ អង្គ** និង កញ្ញា **អេលីហ្សាប៊ែត ស៊ីម៉ុនណូហ្វត** បានផ្តល់នូវការទាមទារដំបូង អំពីសំណងដែលពួកគាត់ចង់បាន។ សហមេធាវីនាំមុខអន្តរជាតិ បានប្រើប្រាស់ឱកាសនោះ ដើម្បីរំលឹកដល់ភាគីទាំងឡាយ និងសាធារណៈជនថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងនៅចំពោះមុខ អ.វ.ត.ក មិនមែនជាភ្ញៀវនោះទេ តែជាតួអង្គសំខាន់នៅក្នុងសវនាការ ដែលមានសិទ្ធិដូចគ្នានឹងភាគីដទៃទៀតដែរ។ គាត់បានបញ្ជាក់នូវក្តីបារម្ភអំពីតម្រូវការដែលមាន "លក្ខណៈវិសាមញ្ញ និងពិសេសដោយឡែក"[31] ចំពោះការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី។ គាត់បានចាត់ទុកតម្រូវការនេះថា "មានលក្ខណៈប្លែកពីតុលាការជាតិ និងអន្តរជាតិ"[32] និងជំរុញថា ចំណុចទាំងនេះមិនត្រូវក្លាយជាឧបសគ្គចំពោះសិទ្ធិរបស់ភាគីក្នុងការទទួលបានសំណងនោះទេ។

សហមេធាវី **ពេជ្រ អង្គ** បានលើកឡើងបន្តទៀត និងបានពន្យល់ថា អង្គការមិនមែនរដ្ឋាភិបាល មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះ បានប្រមូលព័ត៌មានពីដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់ទូទាំងប្រទេសកម្ពុជា។ យោងតាមការពិភាក្សានេះ វាច្បាស់ណាស់ថា ដើមបណ្តឹងរដ្ឋប្បវេណីចង់បាននូវសំណងបួនប្រភេទ។ **ទីមួយ** ៖ ដើមបណ្តឹងរដ្ឋប្បវេណី នឹងសុំដល់អង្គជំនុំជម្រះសាលាដំបូង កំណត់នូវការរំលឹកខួបចងចាំនៃឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងនេះ តាមរយៈការបង្កើតទិវាចងចាំ ការកសាងចេតិយ និងទីតាំងរំលឹកការចងចាំ ព្រមទាំងការអភិរក្សទីតាំងសម្លាប់មនុស្សធំៗ។ **ទីពីរ** ៖ ដើមបណ្តឹងរដ្ឋប្បវេណី នឹងស្នើសុំឲ្យមានការបង្កើតកម្មវិធីព្យាបាលផ្លូវចិត្ត និងការពិគ្រោះយោបល់ ដែលជាកន្លែងពួកគាត់អាចមកជួបជុំគ្នា ចែករំលែកបទពិសោធន៍ និងអាចជួយគ្នាទៅវិញទៅមក ព្រមទាំងទទួលបានការព្យាបាលពីអ្នកចិត្តសាស្ត្រ។ **ទីបី** ៖ ដើមបណ្តឹងរដ្ឋប្បវេណី នឹងស្នើសុំឲ្យមានការបង្កើតកម្មវិធី និងមជ្ឈមណ្ឌលសិក្សា ដូចជា សារមន្ទីរ និងបណ្ណាល័យដើម្បីពង្រីកបន្ថែមការយល់ដឹងអំពីប្រវត្តិសាស្ត្រនៃកម្ពុជាប្រជាធិបតេយ្យ។ ក្នុងនោះដែរ ពួកគាត់ក៏ចង់ឲ្យមានការចងក្រងនូវសៀវភៅ និងឯកសារប្រវត្តិសាស្ត្រសម្រាប់ជនជំនាន់ក្រោយ ក៏ដូចជាការចងក្រងនូវបញ្ជីឈ្មោះរបស់ជនរងគ្រោះដែរ។ **ទីបួន** ៖ ដើមបណ្តឹងរដ្ឋប្បវេណីនឹងស្នើសុំទម្រង់សំណងផ្សេងដទៃទៀត រួមមាន៖ ការផ្សព្វផ្សាយសេចក្តីសម្រេចនៃសំណុំរឿង០០២ ការផ្តល់សញ្ញាតិកម្ពុជាដល់ដើមបណ្តឹងរដ្ឋប្បវេណីជនជាតិវៀតណាម និងការបង្កើតកម្មវិធីសិក្សាពិសេសគាំទ្រដល់កុមារ ដែលកើតចេញមកពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជាចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីនឹងសំណូមពរឲ្យមានការបង្កើតជាមូលនិធិ សម្រាប់ផ្តល់ហិរញ្ញប្បទានទៅលើការទាមទារសំណងទាំងនេះ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកបន្ថែមថា ពួកគាត់

នឹងធ្វើការកែសម្រួលសំណើនេះជាថ្មី ដោយបញ្ចូលនូវគំនិតយោបល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១,៧២៨ នាក់ទៀត ដែលអង្គបុរេជំនុំជម្រះទើបតែទទួលស្គាល់នាពេលថ្មីៗនេះ។

***កំណត់សម្គាល់*** ៖ នៅក្នុងអនុស្សរណៈ ចុះថ្ងៃទី២៣ កញ្ញា ២០១១ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការកត់សម្គាល់ទៅ លើការទាមទារដំបូង ដោយយោងតាមវិធាន ៨០ស្ទួន (៤)។ ការទាមទារ មានន័យថា "គួរចៀសវាងនូវការចំណាយច្រើនហួសហេតុ ការប្រើពេលយូរ ឬការភ័ន្តច្រលំលើការរៀបចំកម្មវិធី" ដើម្បីធានាប្រភពធនធានរបស់អង្គភាពគាំពារជនរងគ្រោះ (ដែលទទួលបន្ទុកលើការរៀបចំកម្មវិធីដែលមិនពាក់ព័ន្ធនឹងបច្ចេកទេសតុលាការ ព្រមទាំងរក្សាលំនឹងសុវត្ថិភាពហិរញ្ញវត្ថុរបស់វា) និងធានានូវលទ្ធផលជាផ្លែផ្ការបស់ អ.វ.ត.ក។ ដូចបានលើកឡើង តុលាការបញ្ជាក់ថា សំណងដែលក្រៅពីសមត្ថកិច្ចរបស់ អ.វ.ត.ក មិនអនុញ្ញាតឲ្យលើកឡើងទេ។ បន្ទាប់ពីបានពិនិត្យនូវការទាមទារដំបូងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អង្គជំនុំជម្រះបានរំឭកដល់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីថា ការបង្កើតមូលនិធិសម្រាប់សំណងសមូហភាព និងសំណងបុគ្គល មិនអាចផ្ដល់ដល់ដើមបណ្ដឹងរដ្ឋប្បវេណីបានទេ ហើយក៏មិនអាចស្នើសុំឲ្យអង្គជំនុំជម្រះធ្វើសេចក្ដីបង្គាប់ឲ្យរដ្ឋាភិបាល អនុវត្តនោះដែរ លុះត្រាណាមានការយល់ព្រមពីរដ្ឋាភិបាល។ អង្គជំនុំជម្រះមិនបានផ្ដល់យោបល់ទៅលើការទាមទារ ផ្សេងដទៃទេ ជាពិសេស ការកសាងសារមន្ទីរ និងទីតាំងរំឭកការចងចាំ ព្រោះថាសំណើទាំងនេះពុំមានមូលដ្ឋាន ច្បាស់លាស់។ បន្ទាប់ពីការបញ្ជាក់ហើយ អង្គជំនុំជម្រះបានប្រកាសថា នឹងមានសវនាការមួយទៀត នៅថ្ងៃទី១៩ តុលា ២០១១ ដោយសារតែចំនួនដើមបណ្ដឹងរដ្ឋប្បវេណីជាច្រើនទើបតែទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ។ តុលាការបានពន្យល់ថា គោលបំណងនៃសវនាការលើកទីពីរនេះ គឺដើម្បីផ្ដល់ឱកាសឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី កែសម្រួលនូវបញ្ជីឈ្មោះថ្មី និងកំណត់ឡើងវិញនូវការទារទារដំបូង ប្រសិនបើចាំបាច់។

**អំពីកម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម** ៖ ជាកម្មវិធីរបស់គម្រោងផ្ដួចផ្ដើមយុត្តិធម៌ប្រចាំអាស៊ី-អន្តរជាតិ (Asian International Justice Initiative) ដែលជាកិច្ចសហការរវាង U.C. Berkeley War Crime Study Center និង East-West Center ។ កម្មវិធីនេះ ចេញផ្សាយរបាយការណ៍ប្រចាំសប្ដាហ៍ ***អំពីដំណើរការនីតិវិធីសវនាការ*** នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ឬហៅកាត់ថា តុលាការកាត់ទោសខ្មែរក្រហម។ បច្ចុប្បន្ន កម្មវិធីនេះកំពុងដំណើរការឃ្លាំមើលសវនាការកាត់ទោសលើសំណុំរឿងក្ដីលេខ ០០២ ប្រឆាំងជនជាប់ចោទចំនួន បួនរូប ៖ លោក នួន ជា លោក អៀង សារី លោក ខៀវ សំផន និងលោកស្រី អៀង ធីរិទ្ធ ។

របាយការណ៍សរសេរដោយក្រុមអ្នកឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម ដែលមានសមាសភាពមកពីប្រទេស ៖ កម្ពុជា ហ្វីលីពីន ស្វីស ថៃ និង សហរដ្ឋអាមេរិក។

លោក-អ្នកអាចស្វែងរករបាយការណ៍នេះបានជាភាសា ខ្មែរ និង អង់គ្លេស តាមរយៈ http://krtmonitor.org/ និង http://socrates.berkeley.edu/~warcrime/ ។

---

1 វិធានផ្ទៃក្នុងអ.វ.ត.ក (វិសោធនកម្មទី៧) ថ្ងៃ២៣ កុម្ភៈ ២០១១

2 ជនជាប់ចោទទាំងបួនរូប The four Accused are charged with genocide by killing members of the groups of Vietnamese and Cham, punishable under Article 4, 29 (new) and 39 (new) of the ECCC Law.

3 Trial Chamber. Transcript of Initial Hearing (27 June 2011). E1/4.1 [hereinafter, INITIAL HEARING TRANSCRIPT 27 JUNE]. Lines 15-16. 11.

4 *Ibid.*, at lines 4-7. 17

5 See also, International Convention on Civil and Political Rights, Art. 14 (7), Cambodian Criminal Procedural Code, Arts. 7 and 12.

6 Pre-Trial Chamber. "Public Decision on Ieng Sary"s Appeal Against the Closing Order" (11 April 2011). D427/1/30 [hereinafter, PTC DECISION].

7 See Statute of the International Criminal Tribunal for the Former Yugoslavia, Art. 10, Statute of the International Criminal Tribunal for Rwanda, Art. 9, Statute of the Special Court for Sierra Leone, Art. 9, Statute of the Special Tribunal for Lebanon, Art. 5, and Rome Statute of the International Criminal Court, Art. 20.

8 INITIAL HEARING TRANSCRIPT 27 JUNE. Lines 23-24. 96.

9 Cayley, referring to Document No. D288/6/9/9.3, INITIAL HEARING TRANSCRIPT. Lines 20-24. 102.

10 The Law on Outlawing the Group of "Democratic Kampuchea", 15 July 1994, is available at <http://www.unhcr.org/refworld/docid/3ae6b51f8.html>, retrieved on, 4 October 2011]. Article 1: "Place the group of 'Democratic Kampuchea" and its troops as outlaws."

11 Sihanouk, Norodom. "A Pardon is Granted to Mr Ieng Sary." (12 May 2011). E51/8.1. Accessible at <http://www.eccc.gov.kh/en>, retrieved on 7 October 2011. Please note that there are at least three differentEnglish translations of this text.

12 See Ahmed, Anees and Quayle, Merryn. "Can Genocide, Crimes against Humanity and War Crimes be Pardoned or Amnestied?" *Amicus Curiae.* Issue 79 (Autumn 2009). 15-20.

13 Trial Chamber. Transcript of Initial Hearing (28 June 2011). E1/5.1 [hereinafter, INITIAL HEARING TRANSCRIPT

28 JUNE]. p. 24 et seq.; Ieng Sary. "Supplement to rule 89 preliminary objection" (Royal pardon and amnesty) (27 May 2011). E51/10 [hereinafter, IENG SARY SUPPLEMENT]. para. 2.B.3, 16 et seq., especially footnote 29, which refers to a "forthcoming supplementary submissions the Defence intends to make on this issue in its supplementary submission on the applicability of international law". See: Ieng Sary. "Indication of the Pre-Trial Chamber"s Decision on Ieng Sary"s Appeal Against the Closing Order Which Require Supplementary Submissions Related to the Application of International Crimes and Forms of Liability at the ECCC" (3 May 2011). E83. par 2.

[14] The Defense argued in IENG SARY SUPPLEMENT para. 2.B.3, 16 et seq. that "the validity of a domestic amnesty in the State where granted is purely a matter of that State's domestic law. The international obligations ofCambodia, a sovereign State, are extraneous when determining the validity of the RPA in a Cambodian court."

[15] The principle of prosecute or extradite constitutes an obligation *erga omnes*, an obligation owed by states towards the community of states as a whole. See also Anees Ahmed and Merryn Quayle, "Can genocide, crimes against humanity and war crimes be pardoned or amnestied?", Amicus Curiae Issue 79 Autumn 2009: 15 é 20.

[16] Provisions dated 10 September 1994 Relating to the Judiciary and Criminal Law and Procedure Applicable in Cambodia during the Transitional Period, Art. 30.

[17] Article 3 and 3(new) ECCC Law.

[18] Trial Chamber. "Public Decision on the Defence Preliminary Objection Concerning the Statute of Limitations of Domestic Crimes" (26 July 2010). E187.

[19] Pre-Trial Chamber. "Public Decision on Ieng Sary"s Appeal against the Closing Order" (11 April 2011). D427/1/30 [hereinafter, DECISION ON IENG SARY"S APPEAL AGAINST CLOSING ORDER].

[20] Case 001. Defense. "Preliminary Objection Concerning Termination of Prosecution of Domestic Crimes" (28 January 2009). E9/1

[21] Constitutional Council of Cambodia Decision (12 February 2001).

[22] Case 001. Trial Chamber. "Decision on the Defence Preliminary Objection Concerning the Statute of Limitations of Domestic Crimes" (26 July 2010). E187.

[23] DECISION ON IENG SARY"S APPEAL AGAINST CLOSING ORDER.

[24] Trial Chamber. Transcript of Initial Hearing (29 June 2011). E1/6.1 [hereinafter, INITIAL HEARING TRANSCRIPT 29 JUNE]. Line 12. 56

[25] INITIAL HEARING TRANSCRIPT 28 JUNE. Lines 22é5. 84-85

[26] ICRC Annual Report 2010. 275 et. seq.

[27] Available at <http://treaties.un.org>, accessed on 12 October 2011

[28] INITIAL HEARING TRANSCRIPT 28 JUNE. Lines 13-15. 106.

[29] ECCC Internal Rules (Rev. 7), Rule 81(1).

[30] Adopted during the ECCC"s 8th Plenary Session on 17 September 2010

[31] INITIAL HEARING TRANSCRIPT 29 JUNE. Line 17. 110.

[32] *Ibid.*, at line 24. 110.